# របាយការណ៍នៃការសិក្សាលឿន

អ្នកមិនបានទៅបោះឆ្នោត ឬអ្នកមិនមានទឹកខ្មៅនៅម្រាមដៃ

# ទំហំនៃការសិក្សា

របាយការណ៍នៃការសិក្សាលឿនលើអ្នកមានសិទ្ធិបោះឆ្នោតក្រោយថ្ងៃបោះឆ្នោតមួយថ្ងៃ មានចំនួន ៧៥៧នាក់ ក្នុងឃុំសង្កាត់ចំនួន ១៧៧ នៃ ២៥រាជធានីខេត្ត។ ទិន្នន័យទាំងនេះវាមិនបង្ហាញជាតួលេខតំណាងអ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតទូទាំងប្រទេសនោះទេ។

# ១.មូលហេតុដែលមិនបានបោះឆ្នោត ឬគ្មានទឹកខ្មៅនៅម្រាមដៃ




ក្នុងចំណោមអ្នកដែលផ្តល់សំភាសន៍ ៤៨% គឺបានទៅដល់ការិយាល័យបោះឆ្នោត តែជួបឧបសគ្គ។ រីឯអ្នកដែលមិនបានទៅការិយាល័យបោះឆ្នោត មានចំនួន ៥២%(ក្នុងចំណោមនោះគឺ ១៥% ចិត្តមិនចង់ទៅបោះឆ្នោត និង៨៥% ចិត្តចង់ទៅបោះឆ្នោតដែរ)។

# ២. ហេតុផលដែលទៅដល់ការិយាល័យបោះឆ្នោត ហើយមិនបានបោះ




ក្នុងចំណោមអ្នកដែលបានទៅដល់ការិយាល័យបោះឆ្នោត ហើយអ្នកទាំងនោះមិនត្រូវបានបោះឆ្នោត ដោយសារតែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណប្រើប្រាស់សំរាប់ការបោះឆ្នោតមានចំនួន ៤៦%។ ៤៣% គឺដោយសារតែគ្មានបណ្ណព័ត៌មាន ដែលពិបាករកលេខការិយាល័យ និងរកឈ្មោះ។ ក្រៅពីនោះគឺ ដោយសារតែការិយាល័យមានភាពរញ៉េរញ៉ៃ និងខុសទិន្នន័យ។

# ៣. សម្រាប់អ្នកមិនបានបោះឆ្នោតតែគាត់ចង់បោះឆ្នោត




សម្រាប់ប្រជាពលរដ្ឋដែលចង់បោះឆ្នោត តែគាត់មិនបានបោះឆ្នោត បានបង្ហាញថា ៦០% គឺពួកគាត់មិនបានទទួលព័ត៌មាន ព្រមទាំងមិនបានចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត។ រីឯ ១៦%ទៀតគឺដោយសារតែទីតាំងនៅឆ្ងាយ ព្រមទាំងថៅកែ កន្លែងធ្វើការមិនឱ្យសំរាក។ រីឯក្នុងចំណោមផ្សេងទៀតគឺដោយសារពួកគាត់ខ្លះរវល់ការងារផ្ទះ ខ្លះថាមិនសំខាន់។

# ៤. អ្នកបោះឆ្នោតដែលមិនបានបោះឆ្នោត ហើយចិត្តពួកគាត់ក៏មិនចង់ទៅបោះឆ្នោត




ក្នុងចំណោមអ្នកបោះឆ្នោតដែលមិនចង់ទៅបោះឆ្នោត គាត់បានបង្ហាញថា ៣៦% គឺខ្ជិល រីឯអ្នកខ្លះមូលហេតុរបស់គាត់គឺ ជាប់រវល់ការងា និងកិច្ចការផ្ទះមានចំនួន ៣៦% ក្រៅពីនោះគឺមិនចូលចិត្តគណបក្ស និងគិតថាមិនមានសារៈសំខាន់។

# និន្នាការភាគរយនៃលទ្ធផលសំឡេងឆ្នោត និងអាសនៈ




- លទ្ធផលដែលទទួលបាន ចំនួន ១៧៦០០ការិយាល័យ

# ការបង្ហាញគេហទំព័រលទ្ធផលឆ្នោត

# អរគុណ